## មជ្ឈមណ្ឌលឯកសារកម្ពុជា

# គម្រោងស្តីពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

## (១៩៧៥–១៩៧៩)

### ការចែកចាយសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ
### វេទិកាសាធារណៈស្តីពីការអប់រំប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ
### រវាងគ្រូ សិស្ស និងឪពុកម្តាយ

**ភូមិវត្តភ្នំ ឃុំកំពែង ស្រុកគីរីវង់ ខេត្តតាកែវ**

**ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១០**



*អ្នកចូលរួមនៅក្នុងការធ្វើវេទិកាសាធារណៈស្តីពីការអប់រំប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ*
*នៅឃុំកំពែង ស្រុកគីរីវង់ ខេត្តតាកែវ*

នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១០ គម្រោងស្តីពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានប្រារព្ធធ្វើវេទិកាសាធារណៈស្តីពីការអប់រំប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ រវាងគ្រូបង្រៀន សិស្សានុសិស្ស និងឪពុកម្តាយ នៅភូមិវត្តភ្នំ ឃុំកំពែង ស្រុកគីរីវង់ ខេត្តតាកែវ ។ អ្នកដែលចូលរួមនៅក្នុងវេទិកានេះរួមមានសិស្សចំនួន៨០នាក់ ប្រជាជនចំនួន៦០នាក់ គ្រូបង្រៀនចំនួន៩នាក់ និងព្រះសង្ឃចំនួន៦អង្គ ។ វេទិការនេះត្រូវបានប្រារព្ធធ្វើឡើងនៅក្នុងបរិវេណវត្តភ្នំ ក្នុងគោលបំណងចែកចាយ និងពិភាក្សាទៅលើសៀវភៅ "ប្រវត្តិសាស្ត្រកម្ពុជា

Documentation Center of Cambodia
Searching for the Truth: Memory & Justice
ស្វែងរកការពិត ដើម្បីការចងចាំនិងយុត្តិធម៌
66 Preah Sihanouk Blvd. • P.O.Box 1110 • Phnom Penh • Cambodia
t (855-23) 211-875 • f (855-23) 210-358 • dccam@online.com.kh • www.dccam.org

ប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» ។ វេទិការនេះបានចាប់ផ្តើមដោយមានការរៀបរាប់យ៉ាងសង្ខេបពីការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា គម្រោងស្តីពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងគោលបំណងនៃការធ្វើវេទិកា ។ បន្ទាប់មកលោកមេឃុំ គង់ ភៀង បានឡើងផ្តល់នូវមតិស្វាគមន៍ដល់អ្នកចូលរួម ហើយគាត់ក៏បាននិយាយអំពីផលប្រយោជន៍នៃការសិក្សាអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ។ លោក ប្រាក់ កែវតារា បានធ្វើបទបង្ហាញពីជំពូក៥នៃសៀវភៅប្រវត្តិសាស្ត្រដែលមានចំណងជើងថា "ភូមិសាស្ត្ររដ្ឋបាលកម្ពុជាប្រជាធិបតេយ្យ" អមទៅដោយកម្មវិធីសំណួរនិងចម្លើយ ដែលឆ្លើយដោយលោក ឌី ខាំបូលី ជាអ្នកនិពន្ធសៀវភៅនេះ ។ នៅពេលរសៀលសមាជិកក្រុមការងារបានធ្វើសម្ភាសជាមួយប្រជាជន និងសិស្សានុសិស្ស ដើម្បីកត់ត្រាទុកនូវបទពិសោធន៍ផ្ទាល់ខ្លួនក្នុងរបបខ្មែរក្រហម និងដើម្បីស្វែងយល់ពីការចាប់អារម្មណ៍របស់ខ្លួនអំពីការសិក្សាពីប្រវត្តិសាស្ត្រខ្មែរក្រហម ។ ផ្នែកមួយចំនួនដែលរៀបរាប់ដូចខាងក្រោម រួមមានការពិពណ៌នាអំពីលក្ខណៈភូមិសាស្ត្រសកម្មភាពនៅពេលធ្វើវេទិកា លទ្ធផល ផលប៉ះពាល់ និងបញ្ហាប្រឈម ។

## លក្ខណៈភូមិសាស្ត្រ

ក្រុមការងារបានទៅដល់ទីតាំងធ្វើវេទិកាមុនមួយថ្ងៃ ដើម្បីរៀបចំការងារ និងបានទៅជួបលោកមេឃុំអំពីការចូលរួម របៀបវារៈសម្រាប់ការធ្វើវេទិកា និងប្រវត្តិរបស់ឃុំដែលទាក់ទងនៅក្នុងរបបខ្មែរក្រហម ។ លោកមេឃុំ គង់ ភៀង បានរៀបរាប់ថា ឃុំកំពែងមាន១៣ភូមិ និងមានប្រជាជនចំនួន១.៨៦៤គ្រួសារ ។ ប្រជាជនសរុបមានចំនួន៧.៦៦៣នាក់ ក្នុងចំណោមនោះមានស្ត្រីចំនួន៣.៩២២នាក់ ។ ឃុំកំពែងមានចម្ងាយប្រមាណ៤០គីឡូម៉ែត្រពីខេត្តតាកែវ ។ យើងអាចធ្វើដំណើរទៅកាន់ឃុំនេះបានតាមផ្លូវពីរខ្សែ ។ នៅរដូវវស្សា ផ្លូវនេះបានខូចដោយសារទឹកភ្លៀងហូរច្រោះ នឹងឡានដឹកទំនិញធំៗ ។ ក្រុមការងារបានចំណាយពេលអស់រយៈពេលប្រហែល២០នាទីក្នុងការធ្វើដំណើរពីទីរួមខេត្តតាមបណ្តោយផ្លូវជាតិលេខ២មកដល់មាត់ច្រកចូលទៅកាន់ឃុំកំពែង ប៉ុន្តែយើងចំណាយពេលច្រើនជាងមួយម៉ោងទៀតក្នុងការធ្វើដំណើរពីផ្លូវជាតិចូលទៅដល់ទីកដីឃុំកំពែង ។

ពេលដែលទៅដល់ឃុំកំពែង ក្រុមការងារបានទៅដល់ផ្ទះរបស់លោកមេឃុំដើម្បីធ្វើការពិភាក្សា ។ បន្ទាប់មក ក្រុមការងាររួមជាមួយលោកមេឃុំបានធ្វើដំណើរទៅវត្តភ្នំ ដែលជាកន្លែងធ្វើវេទិកា ដើម្បីសុំការអនុញ្ញាតពីព្រះចៅអធិការវត្តក្នុងការប្រារព្ធធ្វើវេទិកានៅថ្ងៃបន្ទាប់ ។ ព្រះចៅអធិការបានទទួលស្វាគមន៍ក្រុមការងារយ៉ាងកក់ក្តៅចំពោះការធ្វើវេទិកានេះនិងធានាថា ព្រះអង្គអាចជួយរៀបចំពីទីកន្លែងសម្រាប់ប្រជុំ នឹងឧបករណ៍បំពងសម្លេង ។ ព្រះអង្គក៏បានស្នើសុំឲ្យព្រះសង្ឃទាំងអស់ដែលគង់នៅក្នុងវត្តឲ្យចូលរួមក្នុងវេទិកានេះដែរ ។

គួរកត់សម្គាល់ថា វត្តភ្នំត្រូវបានបំផ្លាញស្ទើរតែទាំងស្រុងក្នុងរបបខ្មែរក្រហម លើកលែងតែអគារបណ្ណាល័យមួយគត់ដែលត្រូវរក្សារទុកសម្រាប់ធ្វើជាមន្ទីរពេទ្យរបស់ខ្មែរក្រហម ។ អនុវិទ្យាល័យសុខអាន ភ្នំ ដែលមានទីតាំងក្បែរនេះ ត្រូវបានខ្មែរក្រហមប្រើប្រាស់ធ្វើជាមន្ទីរពេទ្យឃុំ ។ អាគារសាលារៀន និងបណ្ណាល័យដែលត្រូវបានប្រើប្រាស់ជាមន្ទីរពេទ្យរបស់ខ្មែរក្រហម គឺបានបន្សល់ទុករហូតដល់សព្វថ្ងៃ ។ ព្រះវិហារត្រូវបានសាងសង់ឡើងវិញនៅឆ្នាំ១៩៨៦ ។





**បណ្ណាល័យរបស់វត្តភ្នំ ដែលខ្មែរក្រហមប្រើជាមន្ទីរពេទ្យ** **កន្លែងតម្កល់ឆ្អឹង**

យោងតាមការពិភាក្សារបស់លោកមេឃុំ គង់ ភៀង ជីវភាពនៅក្នុងឃុំកំពែងហាក់មានកម្រិតធូរធារគ្រាន់បើ បើប្រៀបធៀបទៅនឹងសង្គមមុនៗ ។ នាបច្ចុប្បន្ននេះ ទោះជាពុំមានអ្នកភូមិណាម្នាក់មានឡានជិះ ប៉ុន្តែអ្នកភូមិនៅក្នុងឃុំកំពែងមានម៉ូតូជិះរហូតដល់ទៅ៦៣៧គ្រឿង ។ មានវត្តចំនួន៦ និងមណ្ឌលសុខភាពមួយ នៅក្នុងឃុំនេះ ។ ប្រជាជនអាចទទួលបានការព្យាបាលនៅក្នុងឃុំ មិនដូចពីឆ្នាំមុនៗដែលប្រជាជនត្រូវតែធ្វើដំណើរទៅស្រុកគិរីវង្សដើម្បីព្យាបាលជំងឺនោះទេ ។ មានសាលាបឋមសិក្សាចំនួន៦កន្លែងនិងអនុវិទ្យាល័យចំនួនមួយកន្លែង សម្រាប់ការអប់រំពីថ្នាក់ទី៧ដល់ថ្នាក់ទី៩ ។ ក្មេងៗនៅក្នុងឃុំមិនចាំបាច់ធ្វើដំណើរទៅកាន់ទីរួមស្រុកដើម្បីចូលរៀនកម្រិតថ្នាក់ក្នុងអនុវិទ្យាល័យឡើយ ។

លោក គង់ ភៀង ជាមេឃុំនៅឃុំកំពែងពីរអាណត្តិរួចមកហើយ រួមទាំងអាណត្តិនេះ ។ គាត់ក៏ជាមេឃុំកំពែងក្នុងឆ្នាំ១៩៧៩ដែរ ដែលកាលនោះគាត់បានរួមចំណែកក្នុងការកសាងឃុំកំពែងបន្ទាប់ពីរបបខ្មែរក្រហម ។ ដោយសារគាត់រស់នៅក្នុងឃុំកំពែងតាំងពីកំណើត ហើយបានចាកចេញពីស្រុក

កំណើតក្នុងរបបខ្មែរក្រហម និងចូលធ្វើទាហានរបស់របបសាធារណៈរដ្ឋប្រជាមានិតកម្ពុជាតែក្នុងរយៈពេលខ្លី មេឃុំ ភៀង បានដឹងពីប្រវត្តិនិងការអភិវឌ្ឍន៍ក្នុងឃុំកំពែងយ៉ាងច្បាស់ ។ ប្រវត្តិរបស់លោកគង់ ភៀង គឺជាសាច់រឿងមួយក្នុងចំណោមសាច់រឿងជាច្រើនទៀតនៅក្នុងឃុំកំពែងដែលត្រូវតែរក្សាទុក និងរួមចំណែកក្នុងគម្រោងការកសាងប្រទេសឡើងវិញបន្ទាប់ពីអំពើប្រល័យពូជសាសន៍ ។

នៅក្នុងរបបខ្មែរក្រហម ភៀង ក៏ដូចជាប្រជាជនដែលរស់នៅក្នុងភូមិកំពែងដទៃទៀតដែរ បានត្រូវជម្លៀសទៅកាន់ស្រុកត្រាំកក់ ។ ខ្មែរក្រហមបានចាត់ឲ្យប្រជាជនភាគច្រើនដែលរស់នៅឃុំកំពែង និងស្រុកគិរីវង់ជាប្រជាជន១៧មេសា ពីព្រោះអ្នកទាំងអស់នេះរស់នៅជិតព្រំដែនវៀតណាម ។ ប្រជាជនទាំងឡាយណាដែលបានប្រព្រឹត្តិកំហុសឆ្គងបន្តិចបន្តួច ត្រូវបានបង្ខំឲ្យធ្វើការងារធ្ងន់ធ្ងរ ដូចជាផលិតជីឲ្យលេខ១ នៅក្បែរសហករណ៍ខ្មែរក្រហម ។ ចំពោះនរណាដែលបានប្រព្រឹត្តិកំហុសធ្ងន់ធ្ងរ គឺអាចនឹងត្រូវបញ្ជូនទៅកាន់គុកវត្តព្រះធាតុសួស្តីដែលស្ថិតនៅក្នុងឃុំរាមអណ្តើក ។ គុកនេះជាគុកធំរបស់ខ្មែរក្រហមនៅស្រុកគិរីវង្ស ។

នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ១៩៧៩ គណៈកម្មាការប្រជាជនបដិវត្តន៍ឃុំបានបង្កើតការសាងសង់និងការពារឃុំកំពែង ។ ភៀង គឺជាប្រធានគណៈកម្មការនេះ ។ ក្រៅពីការការពារសុវត្ថិភាព ការងារបឋមរបស់គណៈកម្មការនេះ គឺបង្កើតក្រុមសាមគ្គីដែលមានសមាជិកពី១០ទៅ២០គ្រួសារចូលរួមសម្រាប់មួយក្រុម ដែលអាចជួយគ្នាទៅវិញទៅមកក្នុងការផលិតស្រូវ និងចែកចាយចំណីអាហារ ។ “ការត្រលប់ពីរត់មកវិញ” (ជាពាក្យនិយាយដែលចេញមកពីពាក្យ “ពេលត្រលប់មកដល់ភូមិកំណើតវិញក្រោយពីរបបខ្មែរក្រហមដួលរលំ”) ប្រជាជនបានស្នាក់នៅក្នុងឃុំនេះដោយឡែកៗពីគ្នា ។ ការបែងចែកដីធ្លី ត្រូវបានចាត់ចែងឡើងតាមរបៀបអ្នកដែលមកដល់មុន គឺជាអ្នកកាន់កាប់មុន អ្នកដែលមកក្រោយគឺកាន់កាប់ក្រោយ ។ ទោះបីជាប្រជាជនទាំងនោះមិនមែនជាម្ចាស់កម្មសិទ្ធដីធ្លីពិតមែន ប៉ុន្តែគាត់ក៏អាចកាន់ដីធ្លី ឬក៏គោក្របីបានដែរ ។ លោកមេឃុំបាននិយាយថា ពុំមានប្រព័ន្ធអប់រំនៅឃុំរបស់គាត់ទេបន្ទាប់ពីរបបខ្មែរក្រហមត្រូវបានបញ្ចប់ទៅ ហើយក៏ពុំមានចោរលួច ឬចោរប្លន់ដែរ ប៉ុន្តែមានតែទាហានខ្មែរក្រហមដែលរស់នៅលើភ្នំក្បែរៗឃុំនេះប៉ុណ្ណោះ ។ ទោះជាអញ្ចឹងក៏ដោយ ក៏ទាហានខ្មែរក្រហមទាំងនោះបានបំផ្លាញ និងលួចទ្រព្យសម្បត្តិរបស់ប្រជាជន ។ ជានិច្ចកាល កងទ័ពខ្មែរក្រហមទាំងនោះបានចុះចូលជាមួយអាជ្ញាធរមូលដ្ឋាន ហើយបាននាំយកអាវុធជាច្រើនដើមមកប្រគល់ឲ្យគណៈកម្មាធិការប្រជាជនបដិវត្តន៍ស្រុកទៀតផង ។ ភៀង បានកាប់គោមួយក្បាល ដើម្បីធ្វើម្ហូបសម្រាប់ទទួលស្វាគមន៍ទាហានទាំងនោះ ដែលបច្ចុប្បន្ននេះគឺជាប្រជាជនធម្មតាដូចគេឯង ។ ជាមួយនឹងលិខិតអនុញ្ញាតរបស់ ភៀង ទាហានទាំងនោះអាចសម្រេចចិត្តរស់នៅក្នុងឃុំកំពែងក៏បាន ឬវិលទៅរស់នៅស្រុកកំណើតរៀងៗខ្លួនក៏បាន ។

ការខឹងសម្បារ និងអារម្មណ៍សងសឹករបស់ប្រជាជនដែលរស់នៅឃុំកំពែង គឺមានភាពខ្លាំងក្លានៅឆ្នាំ១៩៧៩និងដើមឆ្នាំ១៩៨០ ។ ទាហានខ្មែរក្រហមដែលភ័យខ្លាច បានចុះចូលជាមួយនឹងអាជ្ញាធរមូលដ្ឋាន ហើយក្នុងករណីខ្លះ ទាហានទាំងនោះត្រូវបានសម្លាប់ដោយអ្នកភូមិដែលឪពុកម្ដាយបងប្អូន និងសាច់ញាតិរបស់អ្នកទាំងនោះត្រូវបានសម្លាប់ ឬស្លាប់នៅក្នុងរបបខ្មែរក្រហម ។ ពុំបែបនេះទាហានខ្មែរក្រហមក៏បានចុះចូលជាមួយអាជ្ញាធរមូលដ្ឋាន ហើយអ្នកភូមិក៏បានរៀបចំផែនការពួនស្ទាក់ទាហានខ្មែរក្រហមទាំងនោះ ។ ភឿង បាននិយាយថា «ដោយសារពិបាកទ្រាំ ទាហានខ្មែរក្រហមទាំងនោះបានរត់គេចចេញដោយមិនតបត» ។ ឧប្បត្តិហេតុទាំងនេះបានធ្វើឲ្យមានមនុស្សរបួស និងស្លាប់ជាច្រើននាក់នៅក្នុងព្រៃដែលហ៊ុំព័ទ្ធទៅដោយចម្ការមីន ។ មនុស្សជាច្រើនត្រូវផ្ទុះមីនស្លាប់នាពេលនោះ ។ បន្ថែមពីលើនេះទៅទៀត អ្នកភូមិក៏បានសម្លាប់អតីតកម្មាភិបាលខ្មែរក្រហមដែលជួយស្វែងរកគណ្ដោកបង់ខ្មោចនៅតាមជើងភ្នំជីតាពេជ្រ ។ នៅពេលដែលអ្នកភូមិកំពុងជីករណ្ដៅដើម្បីប្រមូលលលាដ៏ក្បាល និងឆ្អឹងសាកសព អ្នកភូមិទាំងនោះបានត្រឡប់មកវាយសម្លាប់អតីតកម្មាភិបាលទាំងនោះដែលឈរនៅក្បែរៗខ្លួន ។ មើលឃើញនូវសោកនាដកម្មបែបនេះ មេឃុំបានផ្អាកផែនការនេះ ។ លលាដ៏ក្បាល និងឆ្អឹងសាកសពដែលជីកបាន ត្រូវបានរក្សាទុកនៅក្នុងចេតិយ៍មួយក្នុងបរិវេណវត្តភ្នំ ។ មកដល់សព្វថ្ងៃនេះនៅសល់តែឆ្អឹងបន្តិចបន្តួចប៉ុណ្ណោះនៅក្នុងចេតិយនេះ ។

ជីវភាពរស់នៅរបស់ប្រជាជននៅក្នុងឃុំជួបប្រទះការលំបាកណាស់ ។ ពេលមកដល់ស្រុកភ្លាមៗ ប្រជាជនបរិភោគនូវអ្វីៗទាំងអស់ដែលខ្លួនអាចរកបាន ។ ភឿង មានសំណាងជាងគេ ព្រោះបានរកឃើញឃ្លាំងអង្ករបស់ខ្មែរក្រហមដែលគាត់អាចយកបានអង្ករតាមតម្រូវការរបស់គាត់ ។ គាត់ក៏បានចែករំលែកអង្ករខ្លះទៅឲ្យអ្នកភូមិដែលគ្មានសមត្ថភាពរកអ្វីបរិភោគបាន ។ ការជួញដូរផ្សេងៗ មិនមានទេនាសម័យនោះ ហើយប្រជាជនរស់នៅដោយប្រកបរបរធ្វើស្រែចម្ការ ដាំបន្លែ និងបរបាញ់សត្វ ។ ប្រជាជនមួយចំនួនដែលនៅសេសសល់មាសឬប្រាក់ខ្លះៗ បានធ្វើដំណើរទៅកាន់ព្រំដែនវៀតណាមដើម្បីទិញសម្លៀកបំពាក់ របស់របប្រើប្រាស់ផ្សេងៗដែលចាំបាច់សម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃ ។ ពេលខ្លះគ្រួសារពីររស់នៅក្នុងផ្ទះតែមួយ ។

បច្ចុប្បន្ន មានបញ្ហាប្រឈមមួយចំនួនដែលក្រុមប្រឹក្សាឃុំត្រូវតែដោះស្រាយ ។ រដូវប្រាំងដែលមានរយៈពេលវែងពេក បានធ្វើឲ្យអ្នកភូមិនូវពេលវេលាមិនគ្រប់គ្រាន់ដើម្បីធ្វើស្រូវសម្រាប់ចិញ្ចឹមជីវ-ភាពឡើយ ។ អាជ្ញាធរមូលដ្ឋានមានគម្រោងជីកប្រឡាយទឹកដើម្បីនាំយកទឹកបញ្ចូលស្រែ ។ ក្រៅពីនេះជម្លោះដីធ្លី និងអំពើហិង្សាក្នុងគ្រួសារក៏ជាបញ្ហាប្រឈមនៅក្នុងឃុំដែរ ។

ស្រុកគិរីវង់ គឺជាស្រុកដាច់ស្រយាលមួយរបស់ប្រទេសកម្ពុជា ដែលនៅជាប់ព្រំដែនវៀតណាម ហើយដែលស្រុកនេះត្រូវបានហៅថា ស្រុក១០៩ តំបន់១៣ ក្រោមការគ្រប់គ្រងរបស់ តាម៉ុក

លេខាភូមិភាគនិរតី។ យោងតាម ញាណ សុជាតិ ជាអ្នកស្រាវជ្រាវពី “ខ្មែរសន្ទាក់បញ្ហា និងរចនាសម្ព័ន្ធសង្គមនយោបាយនៅភូមិភាគនិរតី” ស្រុក១០៩ ដឹកនាំដោយ ទិត្យ ដែលត្រូវជាប្អូនថ្លៃប្រុសរបស់ តាម៉ុក។ មេភូមិនិងមេឃុំ មិនត្រូវបានជ្រើសរើសចេញពីស្រុកគិរីវង់ទេ អ្នកខ្លះគឺមកពីស្រុកត្រាំកក់ ដែលជាស្រុកកំណើតរបស់តាម៉ុក។

## សកម្មភាពនៅពេលបើកវេទិកា

### ១) ពិធីបើកវេទិកា



លោក ដេង ពង្សរ៉ាស៊ី បានចាប់ផ្តើមបើកវេទិកា ដោយមតិថ្លែងអំណរគុណចំពោះលោកមេឃុំ គង់ ភៀង និងលោកនាយកអនុវិទ្យាល័យ ម៉ែន សន្ធា និងការចូលរួមរបស់អ្នកភូមិ លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សដែលបានចូលរួមក្នុងវេទិកានេះ។ លោកក៏បាន ថ្លែងអំណរគុណចំពោះព្រះចៅអធិការដែលបានផ្តល់កន្លែងធ្វើវេទិកាដល់មជ្ឈមណ្ឌលឯកសារកម្ពុជា។ លោក គង់ ភៀង បានថ្លែងអំណរគុណចំពោះអ្នកចូលរួមទាំងអស់ដែលបានចំណាយពេលវេលាក្នុងថ្ងៃ អាទិត្យមកចូលរួមក្នុងវេទិកានេះ។ គាត់បានប្រាប់ពីគោលបំណងនៃការធ្វើវេទិកាក្នុងការចែកសៀវភៅ “ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)” និងការពិភាក្សាទៅលើមាតិកានៃសៀវភៅ។ គាត់ក៏បានប្រាប់អ្នកចូលរួមទៀតថា សៀវភៅនេះ ត្រូវបានទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា ដែលតម្រូវឲ្យសិស្ស និស្សិតទូទាំងប្រទេសសិក្សាស្វែងយល់ពីសៀវភៅនេះនៅតាមសាលារបស់ខ្លួន។ ទោះជានេះជាតម្រូវការសម្រាប់ការអប់រំយុវជន ប៉ុន្តែមនុស្សវ័យចំណាស់ក៏អាចអានសៀវភៅនេះដើម្បីបង្កើនចំណេះដឹងរបស់គាត់អំពីរបបខ្មែរក្រហមបានដែរ។ លោកបានលើកទឹកចិត្តសិស្សឲ្យចូលរួមយ៉ាងសកម្មនៅក្នុងការពិភាក្សានេះ ហើយលោកក៏បានជម្រុញឲ្យអ្នកភូមិដែលជាឪពុកម្តាយសិស្ស ឲ្យជួយឆ្លើយសំណួរដែលទាក់ទងនឹងបទពិសោធន៍របស់ខ្លួនក្នុងរបបខ្មែរក្រហម។ បន្ទាប់ពីការផ្តល់មតិស្វាគមន៍រួចមក លោកមេឃុំ គង់ ភៀង បានផ្តល់មតិស្វាគមន៍ដល់អ្នកចូលរួមទាំងអស់ និងបានថ្លែងអំណរគុណដល់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានជ្រើសរើសឃុំកំពែងធ្វើជាវេទិកាសាធារណៈក្នុងថ្ងៃនេះ។ លោក គង់ ភៀង បាននិយាយថា វេទិកានេះមានសារសំខាន់

ណាស់ ក្នុងការចែកចាយពត៌មានដែលទាក់ទងទៅនឹងរបបខ្មែរក្រហមដល់អ្នកភូមិ ជាពិសេសក្មេងៗជំនាន់ក្រោយ ។ លោកក៏បានលើកទឹកចិត្តអ្នកភូមិដែលធ្លាប់រស់នៅក្នុងរបបខ្មែរក្រហម ឲ្យជួយចែករំលែកបទពិសោធន៍របស់ខ្លួនដល់កូនចៅជំនាន់ក្រោយដែលកើតក្រោយរបបខ្មែរក្រហម ។ លោកមេឃុំបាននិយាយថា សិស្សគ្រាន់តែបានព្យអំពីរបបខ្មែរក្រហម និងជាទូទៅអ្នកទាំងនោះមិនបានគិតដល់ថារបបនោះជារបបអ្វីឡើយ ហើយប្រជាជនមានការឈឺចាប់យ៉ាងដូច្នេះដែរ ។ នៅចុងបញ្ចប់នៃអនុសាសន៍របស់មេឃុំ គាត់បានប្រកាសបើវេទិកានេះជាផ្លូវការ ។

បន្ទាប់ពីមតិស្វាគមន៍ មេឃុំ គង់ ភៀង បានប្រាប់ពីកម្មវិធីរបស់វេទិកាដែលចាប់ផ្តើមពីម៉ោង៨:៣០ដល់ម៉ោង១១:៣០ព្រឹក ។ គាត់បានបែងចែកសិស្សជាប្រាំមួយក្រុមធំៗ ហើយក្រុមនីមួយៗត្រូវជ្រើសរើសប្រធានក្រុមម្នាក់ ដើម្បីបំពេញជួយដល់ការបំពេញគារាងស្ទាបស្ទង់មតិ ។ សមាជិកគម្រោងទាំងអស់ មាននាទីជួយអ្នកភូមិដែលមិនចេះអាននិងសរសេរក្នុងការបំពេញការស្ទង់មតិនេះ ។ អ្នកចូលរួមត្រូវចំណាយរយៈពេល៣០នាទី ដើម្បីបំពេញការស្ទាបស្ទង់មតិនេះ ។ បន្ទាប់មកក្រុមការងារធ្វើការចែកសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យដល់អ្នកចូលរួមទាំងអស់ ។

## ២) ទស្សនៈរបស់អ្នកចូលរួមអំពីប្រវត្តិសាស្ត្រខ្មែរក្រហម

មុនពេលធ្វើបទបង្ហាញទៅលើជំពូក៩នៃសៀវភៅប្រវត្តិសាស្ត្រ លោក ឌី ខាំបូលី ដែលជាអ្នកនិពន្ធ បានរៀបរាប់សង្ខេបពីប្រវត្តិសាស្ត្រខ្មែរក្រហម ។ បូលី បានសួរទៅកាន់អ្នកចូលរួមថា តើអ្នកទាំងអស់គ្នាបានដឹងពីឈ្មោះ *«របបកម្ពុជាប្រជាធិបតេយ្យ»* ដែរឬទេ? អ្នកភូមិខ្លះបានដឹងពីឈ្មោះនេះ ប៉ុន្តែសិស្សមិនបានដឹងពីឈ្មោះនេះទេ។ បូលី បានពន្យល់ពី «របបកម្ពុជាប្រជាធិបតេយ្យ» ថា គឺជាឈ្មោះផ្លូវការរបស់ខ្មែរក្រហម ដែលត្រូវបានស្គាល់និងប្រើជាទូទៅដោយប្រជាជនដែលរស់នៅក្នុងសម័យនោះ ។

បន្ទាប់មក បូលី ក៏បានសួរថា តើនៅឆ្នាំណាដែលមានរបបខ្មែរក្រហមឡើង? សិស្សម្នាក់បានក្រោកឈរឡើង រួចឆ្លើយថា «ខ្មែរក្រហមចាប់ផ្តើមពីឆ្នាំ១៩៧៥ ដល់ ១៩៧៩» ។

បូលី សួរទៀតថា «តើអ្នកណាដឹងច្បាស់ពីប្រវត្តិសាស្ត្រខ្មែរក្រហម»? សិស្សទាំងអស់ហាក់ដូចជាស្ទាក់ស្ទើរក្នុងការឆ្លើយសំណួរនេះ ។ គាត់ក៏បានពន្យល់ថា អ្នកភូមិដែលធ្លាប់រស់នៅក្នុងរបបខ្មែរក្រហម និងអ្នកដែលកំពុងអង្គុយនៅក្បែរអ្នកឯទៀតនៅទីនោះ បានដឹងច្រើនណាស់អំពីប្រវត្តិសាស្ត្រខ្មែរក្រហម ពីព្រោះគាត់មានបទពិសោធន៍ឈឺចាប់ និងបានឃើញព្រឹត្តិការណ៍ផ្ទាល់ភ្នែកនៅក្នុងអំឡុងពេលនោះ ។ បូលី បានបញ្ជាក់ថា «អ្វីដែលខ្ញុំបានសរសេរនៅក្នុងសៀវភៅនេះ គឺជាហេតុការណ៍ដែលជាប់ទាក់ទងទៅនឹងប្រវត្តិសាស្ត្រខ្មែរក្រហម តាំងពីការបង្កើតបក្ស ជីវិតនៅក្នុងរបបខ្មែរក្រហម និងការដួលរលំរបស់ខ្មែរក្រហម» ប៉ុន្តែការព្រឹត្តិការណ៍ជាក់លាក់នីមួយៗ គឺកើតមាននៅគ្រប់ក្រុមគ្រួសារ

និងគ្រប់ភូមិទាំងអស់នៅក្នុងប្រទេសកម្ពុជា ។ ប្រសិនបើសិស្សចង់ដឹងពីប្រវត្តិសាស្ត្រខ្មែរក្រហមច្រើនបន្ថែមទៀត សូមមើលនៅក្នុងសៀវភៅដែលខ្លួនទើបតែទទួលបាន ឬអាចសួរនាំចាស់ទុំដែលរស់នៅក្បែរខ្លួនជារៀងរាល់ថ្ងៃ ។

បន្ទាប់មក បូលី បានបន្តការពិភាក្សាពីសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ បូលី បានបញ្ជាក់ថា ខេត្តតាកែវគឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់ភូមិភាគនិរតីដែលដឹកនាំដោយ តាម៉ុក (លេខាភូមិភាគ) ។ ដោយឡែកពីនេះទៀត បូលី បាននិយាយពីរណ្តៅសាកសពដែលស្ថិតនៅក្បែរជើងភ្នំជីតាពេជ្រ ក្នុងឃុំកំពែង ។ ឆ្អឹងនិងលលាដ៍ក្បាល ត្រូវបានគាស់ចេញពីរណ្តៅទាំងនោះ ហើយបានដាក់តម្កល់នៅក្នុងវត្តភ្នំ ដែលជាកន្លែងប្រារព្ធធ្វើវេទិកា ។ បូលី ក៏បាននិយាយថា ឆ្អឹងនិងលលាដ៍ក្បាលនៅក្នុងចេតិយ៍ អាចជាសាច់ញាតិរបស់អ្នកដែលបានមកចូលរួមនៅក្នុងវេទិកានាថ្ងៃនេះផង ។

បូលី បានជម្រុញអ្នកចូលរួមទាំងអស់ ជាពិសេសសិស្សានុសិស្សទាំងអស់ ឲ្យខិតខំស្វែងយល់ពីប្រវត្តិរឿងរ៉ាវក្នុងឃុំរបស់ខ្លួន ដែលជាផ្នែកមួយនៃមេរៀនសម្រាប់ជីវិតនិងវិជ្ជាជីវៈទៅថ្ងៃអនាគត និងចូលរួមនៅក្នុងការការពារពីអំពើប្រល័យពូជសាសន៍ ។

បូលី បានសុំឲ្យអ្នកភូមិជួយចែករំលែកបទពិសោធន៍ផ្ទាល់ខ្លួន ក្នុងអំឡុងពេលខ្មែរក្រហម ដល់សិស្សានុសិស្ស ។



**ហោម សុផលៈ** បានឡើងមកខាងមុខវេទិកា ដើម្បីចែករំលែករឿងរ៉ាវរបស់គាត់ ។ សុផល បាននិយាយថា គាត់បានរស់នៅក្នុងរបប ប៉ុល ពត ហើយធ្លាប់ជាគ្រូដែលបង្រៀនពីរបប ប៉ុល ពត កាលពីអំឡុងទសវត្សរ៍ឆ្នាំ១៩៨០ ។ ក្នុងរបបខ្មែរក្រហម កម្មាភិបាលមាន “សិទ្ធិពេញលេញ” ។ អ្នកទាំងនោះអាចសម្លាប់នរណាម្នាក់ដែលខ្លួនចង់សម្លាប់ ។ កម្មាភិបាលខ្មែរក្រហមបានបង្ខំឲ្យប្រជាជនធ្វើការជាច្រើន ប៉ុន្តែបានទទួលរបបអាហារតិចតួច និងមិនគិតពីការឈឺថ្កាត់ ។ ប្រជាជនជម្លៀសត្រូវបានសម្លាប់ដោយមិនអាចលាក់អត្តសញ្ញាណរបស់ខ្លួនបានយូរឡើយ ប្រជាជនដែលជម្លៀសមកពីទីក្រុងភ្នំពេញត្រូវបានសម្លាប់ ។ អ្នកខ្លះបានជីករណ្តៅសម្រាប់កប់ខ្លួនឯងនៅមុនពេលដែលខ្លួនត្រូវបានសម្លាប់ ។

**ហៀ ផន**៖ អ្នកភូមិនៅក្នុងឃុំកំពែង បានលើកទឹកចិត្តអ្នកចូលរួមទាំងអស់ឲ្យយកចិត្តទុកដាក់ស្តាប់ពីការចាប់ផ្តើមបើកវេទិកា និងពិចារណាពីបទពិសោធន៍ពិតដែលខ្លួនបានជួបប្រទះ ។ គាត់បានបន្តថា សិស្សានុសិស្សដែលបានចូលរួមនៅក្នុងវេទិកានេះទាំងអស់ ក៏ដូចជាសិស្សឯទៀត គឺមិនដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមក្នុងអំឡុងពេល៣ឆ្នាំ ៨ខែ និង២០ថ្ងៃនោះទេ ដូច្នេះអ្នកទាំងនោះមិនបានយល់ដឹងពីការឈឺចាប់នៅជំនាន់នោះឡើយ ។ ក្នុងអំឡុងពេលរបបខ្មែរក្រហម ក្មេងៗត្រូវបានប្រើឲ្យដើររើសអាចម៍គោយកមកធ្វើជាជី និងមិនអនុញ្ញាតឲ្យរៀនសូត្រ ។ ផន បានឃើញខ្មែរក្រហមធ្វើគត់ព្រះសង្ឃចំនួន៨អង្គដែលត្រូវបានចោទប្រកាន់ពីបទបានក្បត់នឹងបដិវត្តន៍ ។ គាត់ក៏បានជម្រុញឲ្យសិស្សានុសិស្សទាំងអស់សិក្សាស្វែងយល់ពីសៀវភៅប្រវត្តិសាស្ត្រខ្មែរក្រហមដែលបានផ្តល់ឲ្យ ។ គាត់និយាយទៀតថា "នេះគឺជាប្រវត្តិពិត វាមិនមែនជារឿងនិទានឡើយ ។ សូមប្អូនទាំងអស់គ្នាខិតខំរៀនសូត្រដើម្បីកសាងប្រទេស និងដឹកនាំប្រទេសឲ្យជៀសឆ្ងាយពីរបប ប៉ុល ពត ។

**ឱម រឹម**៖ ជាអ្នកភូមិនៅក្នុងឃុំកំពែង បានរៀបរាប់ពីភាពជូរចត់ និងបទពិសោធន៍នៃការឈឺចាប់ក្នុងអំឡុងពេលខ្មែរក្រហម ។ គ្រួសាររបស់គាត់ត្រូវបានជម្លៀសទៅកាន់ខេត្តពោធិ៍សាត់ ជាកន្លែងដែលកូនទាំងបួនរបស់គាត់ត្រូវខ្មែរក្រហមបំបែកចេញពីគាត់ និងស្លាប់ដោយសារជំងឺ ។ ប្រជាជនដែលមកពីភូមិភាគបូព៌ា ត្រូវបានជម្លៀសទៅកាន់ខេត្តពោធិ៍សាត់និងសម្លាប់ជាទ្រង់ទ្រាយធំ ។ ចាប់តាំងពី រឹម អសមត្ថភាពមក ខ្មែរក្រហមបានឲ្យគាត់នៅមើលស្រែនិងដេញចាប ។ គាត់ពុំបានហូបគ្រប់គ្រាន់ឡើយ ។ ឱម រឹម នៅចងចាំបទចំរៀងរបស់ខ្មែរក្រហមដែលលើកទឹកចិត្តប្រជាជនឲ្យខិតខំបង្កបង្កើនផល ។ គាត់ក៏បានច្រៀងចំរៀងនោះឲ្យអ្នកដែលបានចូលរួមទាំងអស់ស្តាប់ ។

## ៣ ការធ្វើបទបង្ហាញពីសៀវភៅប្រវត្តិសាស្ត្រខ្មែរក្រហម ដោយលោក ប្រាក់ កែវតារា



លោក ប្រាក់ កែវតារា បានធ្វើបទបង្ហាញជំពូក៩ដែលនិយាយពី "ភូមិសាស្ត្ររដ្ឋបាលកម្ពុជាប្រជាធិបតេយ្យ" ។ គាត់បានឲ្យអ្នកចូលរួមទាំងអស់បើកសៀវភៅប្រវត្តិសាស្ត្រត្រង់ទំព័រទី២៨ ដើម្បីចាប់ផ្តើមធ្វើបទបង្ហាញនិងពិភាក្សា ។

កែវតារា បានប្រាប់ពីគោលបំណងនៃការធ្វើបទបង្ហាញរបស់ខ្លួន ដោយអនុញ្ញាតិឲ្យអ្នកចូលរួមទាំងអស់មានលទ្ធភាពអធិប្បាយពីភូមិសាស្ត្ររដ្ឋបាលកម្ពុជាប្រជាធិបតេយ្យ ធ្វើការប្រៀបធៀបរវាង

ភូមិភាគមួយនិងតំបន់មួយ ទៅនឹងភូមិភាគនិងតំបន់ផ្សេងទៀត ហើយធ្វើការវិភាគពីភាពខុសគ្នានឹងភូមិសាស្ត្រប្រទេសកម្ពុជានាពេលបច្ចុប្បន្ន ។ កែវ តារា ក៏បានភ្ជាប់ការពិភាក្សាពីភូមិសាស្ត្រដែលមានរៀបរាប់នៅក្នុងសៀវភៅប្រវត្តិសាស្ត្រ ទៅនឹងលក្ខណៈភូមិសាស្ត្រនៅស្រុកគីរីវង់ដែលមានឈ្មោះថា ស្រុក ១០៩ នាពេលបច្ចុប្បន្ន ។

បន្ទាប់មក កែវ តារា បានបែងចែកអ្នកចូលរួមទាំងអស់ជា៦ក្រុម៖ ២ក្រុមជាអ្នកភូមិ និង៤ក្រុមទៀតជាសិស្ស ។ ក្រុមនីមួយៗ ត្រូវអានមួយចំណងជើងតូចនៃសៀវភៅប្រវត្តិសាស្ត្រខ្មែរក្រហម ពន្យល់ពីផ្នែកដែលបានអាន និងកត់ត្រាចំណុចសំខាន់ៗចំនួន៥ ។

- ក្រុមទី១ អានពីចំណុចភូមិភាគបូព៌ា ។
- ក្រុមទី២ អានពីចំណុចភូមិភាគនិរតី ។
- ក្រុមទី៣ អានពីចំណុចភូមិភាគឧត្តរ ។
- ក្រុមទី៤ អានពីចំណុចភូមិភាគពាយ័ព្យ ។
- ក្រុមទី៥ អានពីចំណុចភូមិភាគបស្ចឹម ។
- ក្រុមទី៦ អានពីចំណុចភូមិភាគឦសាន ។

អ្នកចូលរួមត្រូវចំណាយពេលពី៧ ទៅ១០នាទី ដើម្បីអាននិងពិភាក្សាពីប្រធានបទរៀងៗខ្លួន ។ បន្ទាប់ពីអានចប់ តំណាងក្រុមនីមួយៗឡើងមកចែករំលែកចំណេះដឹង និងការគិតរបស់ខ្លួនពីចំណុចដែលបានអាន ។ កែវ តារា បាននិយាយថា «នៅឆ្នាំ១៩៧៦ ប្រទេសកម្ពុជាត្រូវបានបែងចែកទៅជា៦ភូមិភាគ និង៣២តំបន់» ។ ភូមិភាគទាំងនោះរួមមាន ភូមិភាគបូព៌ា ភូមិភាគនិរតី ភូមិភាគឧត្តរ ភូមិភាគពាយ័ព្យ ភូមិភាគបស្ចឹម និងភូមិភាគឦសាន ។ ភូមិភាគមួយ មានការរួមបញ្ចូលគ្នានូវខេត្តចំនួនពីរ ឬច្រើនជាងនេះ ។ ខ្មែរក្រហមបានដាក់ឈ្មោះស្រុក និងខេត្តជាលេខ ។

បន្ទាប់មក កែវ តារា បានចោទជាសំណួរទៅកាន់អ្នកចូលរួមទាំងអស់ ដើម្បីស្វែងយល់ពីចំណេះដឹងរបស់អ្នកចូលរួម ។ គាត់ក៏បានលើកទឹកចិត្តដល់អ្នកចូលរួមទាំងអស់ឲ្យចេះជួយចែករំលែកបទពិសោធន៍ និងចំណេះដឹងរបស់ខ្លួន ដល់អ្នកចូលរួមទាំងអស់ ។ កែវ តារា បានសួរថា «ហេតុអ្វីបានជាខ្មែរក្រហមដាក់ឈ្មោះតំបន់ ឬភូមិភាគជាលេខ?» ។

អ្នកភូមិម្នាក់បានងើបឈរឆ្លើយនឹងសំណួរ «ប៉ុល ពត ប្រើប្រាស់លេខកូដ ដើម្បីជាការសម្ងាត់» ។ អ្នកភូមិម្នាក់ទៀតឈ្មោះ ងឹម បាននិយាយថា «លេខកូដ ត្រូវបានប្រើប្រាស់ដើម្បីងាយស្រួលសម្រាប់មេដឹកនាំខ្មែរក្រហមក្នុងការដឹកនាំប្រទេស» ។

កែវ តារា បានសួរថា «តើភាពខុសគ្នារវាងការបែងចែកភូមិសាស្ត្រក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងរបបនាពេលបច្ចុប្បន្ននេះ គឺជាអ្វី»

បុរសម្នាក់បានឆ្លើយថា "ខ្មែរក្រហមប្រើលេខសំគាល់ដើម្បីដាក់ឈ្មោះខេត្ត និងស្រុក ខណៈពេលដែលរបបសព្វថ្ងៃនេះប្រើឈ្មោះដូចជា ខេត្តតាកែវ ឬ ស្រុកគិរីវង់" ។

បុរសម្នាក់ទៀតបានចែករំលែកការគិតរបស់គាត់ ហើយបញ្ជាក់ថា "របបខ្មែរក្រហមនិងរបបបច្ចុប្បន្ននេះ គឺមានភាពខុសគ្នាដូចមេឃ ហើយនឹងដី" ។ ប្រជាជនមិនអាចស្វែងរកអាហារសម្រាប់បរិភោគបានគ្រប់គ្រាន់ឡើយនៅក្នុងរបបប៉ុល ពត ។ ប៉ុន្តែក្នុងសម័យ ហ៊ុន សែន វិញ មានសាលារៀន និងមន្ទីរពេទ្យជាច្រើន ត្រូវបានសាងសង់ឡើង ។



កែវតារា បានសួរទៀតថា "តើការបែងចែកភូមិសាស្ត្រក្នុងរបបខ្មែរក្រហម មានភាពងាយស្រួលជាងការបែងចែកនៅក្នុងពេលបច្ចុប្បន្នឬ?

បុរសម្នាក់បានឆ្លើយថា សម័យបច្ចុប្បន្នមានភាពងាយស្រួលជាងសម័យប៉ុល ពត ។ សម័យឥឡូវប្រើឈ្មោះពិតប្រាកដសម្រាប់ដាក់ឈ្មោះខេត្តនីមួយៗ ប៉ុន្តែខ្មែរក្រហមបានប្រើប្រាស់លេខសម្រាប់ដាក់ឈ្មោះខេត្ត ឬស្រុក គឺដើម្បីលាក់អត្តសញ្ញាណខ្លួនពីសត្រូវ" ។

នៅចុងបញ្ចប់នៃការពិភាក្សា លោកមេឃុំ គង់ ភៀង បានចែករំលែកគំនិតរបស់គាត់ខ្លះទៅកាន់អង្គវេទិកាទាំងមូល ដូចដែលគាត់បានស្តាប់សំណួរបីដែលសួរដោយ កែវតារា ។ លោកមេឃុំ បានបញ្ជាក់ថា "ប៉ុល ពត អៀង សារី បានដឹកនាំប្រទេសខុសប្លែកពីមេដឹកនាំឯទៀតនៅក្នុងពិភពលោក" ។ កម្ពុជាពុំធ្លាប់មានបទពិសោធន៍ដឹកនាំនៅក្នុងរបបខ្មែរក្រហមទេ (ការដឹកនាំមួយ) ដែលបានលុបបំបាត់នូវកេរ្តិ៍ដំណែលរបស់ជាតិ ។ កម្មាភិបាលថ្នាក់ទាប មិនបានយល់ដឹងច្បាស់ពីការបែងចែកភូមិសាស្ត្រក្នុងរបបខ្មែរក្រហម ប៉ុន្តែបច្ចុប្បន្ននេះប្រជាជនកម្ពុជាទូទៅបានដឹងច្បាស់ថា ប្រទេសកម្ពុជាត្រូវបានបែងចែកទៅជា២៤ខេត្តក្រុង ។

លោក ម៉ែន សត្ថា ជានាយកអនុវិទ្យាល័យក៏បានចែករំលែកបទពិសោធន៍របស់គាត់ដល់អ្នកចូលរួមទាំងអស់ស្តាប់ ។ គាត់ចង់រៀបរាប់ឲ្យលម្អិតពីភាពខុសគ្នារវាងរបបខ្មែរក្រហម និងរបបបច្ចុប្បន្ននេះ ។ គាត់បាននិយាយថា "នៅក្នុងវិស័យសេដ្ឋកិច្ច ប្រជាជនត្រូវបានគេបង្ខំឲ្យធ្វើស្រែទាំងយប់ទាំង

ថ្ងៃ និងវែកទឹក វែកដីធ្វើទំនប់និងប្រឡាយ ។ តើការហូបចុកវិញយ៉ាងម៉េចដែរ? ប្រជាជនគឺទទួលបានតែរបបបបររាវពីរពេលក្នុងមួយថ្ងៃ។ ប្រសិនបើយើងរកអ្វីបានបរិភោគ យើងនឹងមានគ្រោះថ្នាក់ជាមិនខាន ។ ក្មេងៗរៀននៅក្រោមម្លប់ដើមឈើ ហើយបង្រៀនត្រឹមតែ ក ខ គ...។ ក្មេងតូចៗត្រូវឲ្យបោចស្មៅ រើសអាចម៍គោធ្វើជី ។ គោលការណ៍នៃរបបកម្ពុជាប្រជាធិបតេយ្យគឺបណ្តុះការអប់រំផ្នែកនយោបាយទៅអ្នកដែលមិនចេះអក្សរ ដែលងាយស្រួលដើរតាមការបញ្ចុះបញ្ចូល ។ នៅក្នុងវិស័យសុខភាពវិញ គឺមានតែគណៈឃុំ ប្រធានក្រុម និងមេទាហានប៉ុណ្ណោះដែលមានសុខភាពល្អ ។ ខ្លួនខ្ញុំផ្ទាល់ហូបក្តាមជាមួយនឹងស្លឹកឈើ គ្មានថ្នាំពេទ្យសម្រាប់ព្យាបាលឡើយ គឺមានតែថ្នាំអាចម៍ទន្សាយប៉ុណ្ណោះ ។ អ្នកគ្រប់គ្រងនៅក្នុងភូមិអាចធ្វើអ្វីបានតាមតែខ្លួនចង់ធ្វើ ។ កម្មាភិបាលទាំងនោះបានឲ្យប្រជាជនធ្វើជាអ្នកស៊ើបការណ៍ជាមួយនឹងប្រជាជនឯទៀត ហើយអ្នកទាំងនោះធ្វើការកាប់សម្លាប់គ្នាទៅវិញទៅមក ។ បងប្រុសសម្លាប់ប្អូនប្រុស ។ ក្នុងវិស័យព្រះពុទ្ធសាសនាវិញ វត្តភ្នំ ត្រូវបានបំផ្លាញទាំងស្រុង នៅសល់តែបណ្ណាល័យមួយគត់ដែលកម្មាភិបាលខ្មែរក្រហមប្រើប្រាស់ធ្វើជាកន្លែងធ្វើការរបស់ខ្លួន ។ ពិធីរៀបការបានធ្វើឡើងតាមទ្រង់ទ្រាយធំមួយ គឺ៤០គូរក្នុងពេលតែមួយ ។ ពុំមានពិធីបុណ្យតាមលក្ខណៈសាសនាឡើយ ។ របបខ្មែរក្រហមគឺជារបបដ៏ឃោរឃៅមួយ ។ វេទិកាថ្ងៃនេះគឺរៀនអំពីអ្វីដែលបានកើតឡើងនៅពេលនោះ ក្នុងគោលបំណងជៀសវាងសោកនាដកម្មនៅថ្ងៃអនាគត ។”

លោក ឌី ខាំបូលី បានថ្លែងអំណរគុណចំពោះលោកនាយកអនុវិទ្យាល័យ នូវការវែកញែកក្នុងរបបខ្មែរក្រហម ។ លោកនាយកអនុវិទ្យាល័យបានរំឭកទៀតថា ទិដ្ឋភាពនៅក្នុងប្រវត្តិសាស្ត្រខ្មែរក្រហមរួមមានការអប់រំ សុខភាព សាសនា ប្រពៃណីទំនៀមទំលាប់ សន្តិសុខ និងការរស់នៅប្រចាំថ្ងៃ។ បូលីបាននិយាយប្រាប់អ្នកចូលរួមឲ្យអានជំពូក៧ នៃសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ប្រសិនបើចង់ស្វែងយល់អំពីអ្វីដែលលោកនាយកអនុវិទ្យាល័យបាននិយាយ ។

## ៤) សំណួរ នឹងចម្លើយ

បន្ទាប់ពីការធ្វើបទបង្ហាញពីជំពូក៥ និងពន្យល់រួចមក លោក ឌី ខាំបូលី បានដឹកនាំការសួរសំណួរ និងចម្លើយដល់អ្នកចូលរួមទាំងអស់ ។

១).សុជាត មកពីភូមិហាន់ទា ឃុំកំពែង៖ ហេតុអ្វីបានជា ប៉ុល ពត បង្កើតរបបនេះដើម្បីសម្លាប់ប្រជាជន?

បូលី បានសង្កត់ធ្ងន់ថា សំណួរនេះត្រូវបានប្រជាជនកម្ពុជាជាច្រើនលើកជាសំណួរ នៅពេលដែលខ្លួនបានឆ្លងកាត់របបនេះ ។ ហេតុអ្វីបានជាខ្មែរក្រហមសម្លាប់ប្រជាជន? ហេតុអ្វីបានជាខ្មែរក្រហមបង្ខំប្រជាជនឲ្យធ្វើការងារធ្ងន់ និងរស់នៅដាច់ដោយឡែកពីក្រុមគ្រួសារ? ហេតុអ្វីបាន ជាខ្មែរក្រហមអនុវត្តន៍នយោបាយនេះ? តើអ្នកណាជាអ្នកបង្កើតនយោបាយនេះ? តើពួកគេមានគោល

បំណងអ្វី? ប៊ូលី បាននិយាយថា ការបកស្រាយពីហេតុផលនយោបាយមួយចំនួនទាក់ទងនឹងថា តើហេតុអ្វីបានជាខ្មែរក្រហមសម្លាប់ប្រជាជននៅក្នុងចន្លោះឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩? ប៊ូលី បានឆ្លើយថា មេដឹកនាំខ្មែរក្រហម ជាពិសេសប៉ុល ពត ជឿថាសង្គមកម្ពុជាត្រូវបានកាន់កាប់ដោយការស៊ីសំណូកសូកប៉ាន់ កេងប្រវ័ញ្ចប្រយោជន៍អ្នកដទៃ និងអយុត្តិធម៌។ អ្នកស្រែចម្ការដែលរស់នៅតាមទីជនបទត្រូវបានកេងប្រវ័ញ្ចផលប្រយោជន៍ដោយមន្ត្រីរដ្ឋាភិបាល និងអ្នកមាន។ ដូច្នេះហើយទើប ប៉ុល ពត ចង់បង្កើតប្រទេសកម្ពុជាឲ្យក្លាយទៅជាប្រទេសទំនើបមួយក្នុងសាកលលោក ដែលជាប្រទេសគ្មានសង្គមវណ្ណៈ ហើយការរស់នៅ ការធ្វើការ និងការចែករំលែកគ្នា នូវសេចក្តីរីករាយ គឺមានភាពស្មើៗគ្នា។ គាត់ចង់បង្កើតប្រទេសដែលមានឯករាជ្យភាព មិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់ប្រទេសដទៃ។ គាត់ជឿជាក់ថា ការពឹងពាក់និងទុកចិត្តទៅលើប្រទេស បានត្រឹមតែធ្វើឲ្យពួកគេអាចបញ្ជ្រៀតចូលប្រពៃណីមិនស្មើភាពមកក្នុងកម្ពុជា។ មេដឹក នាំខ្មែរក្រហមជឿថាការរាំច្រៀង ធ្វើការនៅបន្ទប់ម៉ាស៊ីនត្រជាក់ ឬរៀននៅតាមសាលាឬមហាវិទ្យាល័យ មិនអាចជួយក្នុងការបង្កបង្កើនផលបានឡើយ។ ពួកគេបានបំបាត់អស់រលីងនៅពេលនោះ។ ខ្មែរក្រហម ចង់ឲ្យអ្នកដែលរស់នៅទីក្រុងមករស់នៅស្រែចម្ការវិញ ដើម្បីធ្វើការនៅក្នុងស្រែ។ ម្យ៉ាងទៀត ការធ្វើស្រែមិនផ្តោតសំខាន់ទៅលើការប្រើប្រាស់ម៉ាស៊ីន ឬ ជីគីមីឡើយ។ ខ្មែរក្រហមមិនជឿលើសាសនាព្រះពុទ្ធ ព្រះយេស៊ូ អបិយជំនឿ ឬខ្មោចព្រាយបិសាចឡើយ។ ការធ្វើកសិកម្មពឹងពាក់ទៅលើកម្លាំងមនុស្ស។ ប្រជាជនត្រូវធ្វើការលើកទំនប់ប្រឡាយដើម្បីបញ្ចូលទឹកទៅក្នុងស្រែ។ ខ្មែរក្រហមមិនពឹងផ្អែកទៅលើធម្មជាតិទេ។ សម្រាប់ពួកគេ ស្រូវគឺជាអ្វីៗទាំងអស់។ នេះគឺហេតុផលមួយដែលខ្មែរក្រហមជម្លៀសប្រជាជនពីទីក្រុងទៅកាន់ទីជនបទ ដែលជាលទ្ធផលដែលនាំឲ្យមានការកាប់សម្លាប់មនុស្ស។

ម្យ៉ាងទៀតខ្មែរក្រហមចង់ឲ្យប្រជាជនមានជីវិតរឹងប៉ឹង។ គោលបំណងនេះ ពួកគេបានបង្ខំប្រជាជនឲ្យធ្វើការ ឲ្យធ្វើកសិកម្មនិងលើកទំនប់ទឹករាប់ម៉ោងក្នុងមួយថ្ងៃ។ បន្ទាប់ពីធ្វើការរួច ប្រជាជនត្រូវតែចូលរួមប្រជុំជារៀងរាល់ថ្ងៃដែលពួកគេអាចសុំឲ្យមានការតិតៀន នឹងរាយការណ៍ពីខ្លួនឯងជាសាធារណៈ។ ខ្មែរក្រហមបានយកពេលវេលានេះ ដើម្បីពង្រឹងសមត្ថភាពរបស់ប្រជាជនដែលដើរតាមមាគ៌ាបដិវត្តន៍ខ្មែរក្រហម។ វានឹងគ្មានការប្រែប្រួល និងលុបបំបាត់បានឡើយ។ ប៊ូលី បាននិយាយថា ទាំងនេះគឺជាហេតុផលដែលប្រជាជនភាគច្រើនស្លាប់ក្នុងរបបខ្មែរក្រហម។



*២) .ឃុន ស្រីលីន ជាសិស្សមកពីអនុវិទ្យាល័យ សុខ អាន ភ្នំ៖ «ប្រជាជនបង្កបង្កើនផលស្រូវបានជាច្រើនក្នុងមួយឆ្នាំៗ តើខ្មែរក្រហមយកស្រូវទាំងនោះទៅឯណា?»*

ប្រជាជនជាទូទៅនៅទីក្រុងធ្វើការនៅឯស្រែ ទាំងអស់គ្នា ។ សូម្បីតែព្រះសង្ឃក៏ត្រូវខ្មែរក្រហមចាប់ញផ្សឹក និងឲ្យទៅធ្វើស្រែដែរ ។ តើខ្មែរក្រហមយកស្រូវទាំងនោះទៅកន្លែងណា? បូលី បានឆ្លើយនឹងសំណួរនេះថា ផលិតផលស្រូវមិនមានគ្រប់តាមចំនួនកំណត់ពីអង្គការឡើយ ។ ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ កម្មាភិបាលនៅតាមតំបន់ និងសហករណ៍មិនហ៊ានរាយការណ៍ពីផលិតផលស្រូវដែលមិនគ្រប់គ្រាន់ទៅកាន់អង្គការថ្នាក់លើឡើយ ។ គេបញ្ជូនស្រូវជាច្រើនតាមតែអាចធ្វើទៅបាន ដើម្បីឲ្យលើសពីការកំណត់ និងធ្វើឲ្យប្រជាជនមានការអត់ឃ្លាន ។ ស្រូវមួយចំនួនត្រូវបញ្ជូនទៅកាន់ព្រំដែន ដើម្បីចិញ្ចឹមទាហាននៅតាមសមរភូមិដែលកំពុងធ្វើការវាយប្រហារជាមួយកងទ័ពវៀតណាម ។ ស្រូវមួយចំនួនទៀតត្រូវបានបញ្ជូនទៅឲ្យប្រទេសចិន ដើម្បីប្តូរយកអាវុធយុទ្ធភ័ណ្ឌ ។ ស្រូវដែលនៅសេសសល់មួយចំនួន ត្រូវទុកសម្រាប់ប្រជាជន ។ ទាំងនេះគឺជាហេតុផលមួយ ដែលអង្ករមួយកំប៉ុងត្រូវដាំបបរសម្រាប់ប្រជាជន៣០នាក់ ហើយដែលធ្វើឲ្យប្រជាជនជួបភាពអត់ឃ្លាន ។

*៣) លោកគ្រូម្នាក់មកពីអនុវិទ្យាល័យសុខ អាន ភ្នំ បានសួរថា «តើខ្មែរក្រហមមកពីណា?»*

បូលី បានឆ្លើយថាចម្លើយរបស់សំណួរនេះគឺមាននៅក្នុងជំពូក២ នៃសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ បូលី បានឆ្លើយយ៉ាងសង្ខេបថា ចលនាកុម្មុយនីស្តនៅកម្ពុជា បានចាក់ឫសគល់តាំងពីជំនាន់អាណានិគមបារាំងមកម្ល៉េះ ។ ចលនាមួយនេះមានរូបរាងឡើងនៅក្នុងរបបកុម្មុយនីស្តដែលមានឈ្មោះហៅថា បក្សប្រជាជនបដិវត្តន៍ខ្មែរ ដឹកនាំដោយ សឺង ង៉ុកមិញ និងទទួលបានការគាំទ្រដោយវៀតណាមខាងជើង ។ បន្ទាប់ពីលទ្ធិនេះទៅ បន្តដល់លទ្ធិកុម្មុយនីស្តកម្ពុជាដឹកនាំដោយ ប៉ុល ពត ។ បក្សនេះជាបក្សដែលកាន់លទ្ធិកុម្មុយនីស្តទទួលបានជ័យជំនះលើរដ្ឋាភិបាល លុន នុល ឆ្នាំ ១៩៧៥ ។

*៤) សំ សុធី ជាសិស្សមកពីអនុវិទ្យាល័យសុខ អាន ភ្នំ បានសួរថា តើអ្នកណាជាមេដឹកនាំខ្មែរក្រហម? តើសព្វថ្ងៃពួកគេនៅមានជីវិតដែរឬទេ?*

បូលី ៖ មេដឹកនាំខ្មែរក្រហមមានដូចជា ប៉ុល ពត (លេខាបក្ស) នួន ជា (អនុលេខាបក្ស) អៀង សារី ខៀវ សំផន អៀង ធីរិទ្ធ តាម៉ុក សុន សេន និង កែ ពក ទាំងអស់នេះ គឺជាសមាជិករបស់គណៈកម្មាធិការមជ្ឈិមបក្ស និងជាសមាជិករបស់កម្ពុជាប្រជាធិបតេយ្យ ។ បន្ថែមពីនេះ អៀង សារី ធ្លាប់ជាគណៈកម្មាធិការមជ្ឈិមបក្ស និងនាយករដ្ឋមន្ត្រីទទួលបន្ទុកផ្នែកកិច្ចការបរទេស ។ វន វ៉េត ធ្លាប់ជាឧបនាយករដ្ឋមន្ត្រីទី២ ទទួលបន្ទុកផ្នែកសេដ្ឋកិច្ច និង សុន សេន ជាឧបនាយករដ្ឋមន្ត្រីទី៣ ទទួលបន្ទុកកិច្ចការពារជាតិ ។ អ្នកទាំងនេះបានបង្កើតនយោបាយជាតិដែលដឹកនាំការ សម្លាប់ទូទាំងប្រទេស ។ មេដឹកនាំខ្មែរក្រហមដែលនៅមានជីវិតសព្វថ្ងៃនេះ ត្រូវបានឃុំខ្លួន និងបានបញ្ជូនទៅកាន់សាលាក្តីកាត់ទោសខ្មែរក្រហម ។ អ្នកដឹកនាំទាំងនោះរួមមាន ខៀវ សំផន អៀង សារី អៀង ធីរិទ្ធ និង នួន ជា ។ លោក ឌី ខាំបូលី បានប្រាប់ឲ្យដឹងដែរថា ប្រសិនបើអ្នកចូលរួមទាំងអស់ចង់ស្វែងយល់ឲ្យកាន់តែច្បាស់ថែមទៀត សូមអានឯកសារដែលទាក់ទងនឹងមេដឹកនាំទាំងបួនរូប គឺសំណុំរឿង០០២ ។

៥) អ៊ុង ចាន់ដា សិស្សមកពីអនុវិទ្យាល័យសុខ អាន ភ្នំ៖ នៅក្នុងរបបខ្មែរក្រហម ប្រជាជនមិនមានការទុកចិត្តទៅលើគ្នាទៅវិញទៅមកទេ ។ ប្រជាជនរស់នៅដោយលំបាក និងទ្រាំរស់ដោយខ្លួនឯង ។ ហេតុអ្វីបានជាប្រជាជនមិនជឿទុកចិត្តទៅលើគ្នាទៅវិញទៅមក? ហេតុអ្វីបងប្អូនមិនជឿជាក់លើបងប្អូនខ្លួនឯង?

អ្នកភូមិម្នាក់ឈ្មោះ ងីម បានជួយឆ្លើយនឹងសំណួរនេះ ។ គាត់បានបញ្ជាក់ថា មានប្រជាជនមួយចំនួនមិនហ៊ាននិយាយរកគ្នាឡើយ ពីព្រោះខ្លាចមេកងដ៏ឃោរឃៅសម្លាប់ដោយមិនពិចារណា ។



ប្រជាជនត្រូវបានបំភ័យដោយពាក្យសម្ដីដោយមិនចាំបាច់ប្រើប្រាស់អាវុធឡើយ ។ ទោះជាប្រជាជនដែលធ្វើឲ្យបាក់ស្នាបព្រារបស់ខ្លួន ក៏ត្រូវខ្មែរក្រហមចោទប្រកាន់ថាជាខ្មាំងសត្រូវ ហើយត្រូវនាំយកទៅសម្លាប់ចោល ។

## លទ្ធផល និងផលប៉ះពាល់

*ការផ្សព្វផ្សាយព័ត៌មាន* ៖ ពុំសូវមានមន្ត្រីរដ្ឋាភិបាល ឬបុគ្គលិកអង្គការក្រៅរដ្ឋាភិបាលមួយចំនួនបានទៅដល់ឃុំកំពែង ដើម្បីប្រារព្ធវេទិកាសាធារណៈស្ដីពីការអប់រំទេ ជាពិសេសការអប់រំពីប្រវត្តិសាស្ត្រខ្មែរក្រហមនោះឡើយ ។ អ្នកចូលរួមមានអារម្មណ៍ថាសប្បាយរីករាយ ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានចុះមកតំបន់ដាច់ស្រយាលមួយនេះ ដើម្បីផ្សព្វផ្សាយនូវប្រវត្តិរបស់របបខ្មែរក្រហមដល់អ្នកភូមិ ។ ហេតុដូលទាំងនេះ យើងអាចកត់សំគាល់ឃើញថាចំនួនអ្នកភូមិ និងសិស្សានុសិស្សមានចំនួនប្រហាក់ប្រហែលគ្នា ។

*ទស្សនាវដ្ដី* ៖ សាលាឃុំកំពែងបានទទួលទស្សនាវដ្ដីស្វែងរកការពិតពីមជ្ឈមណ្ឌលឯកសារកម្ពុជាទៀងទាត់ពេលវេលា ។ ពេលដែលទៅដល់ផ្ទះរបស់លោកមេឃុំ យើងទាំងអស់គ្នាបានឃើញទស្សនាវដ្ដីទាំងនោះ ។ លោកមេឃុំបានប្រាប់ថា គាត់បានទទួលនូវទស្សនាវដ្ដីទាំងនេះនៅសាលាឃុំ គាត់បានបែងចែកដល់អ្នកភូមិដែលគាត់បានទទួលពីទីរួមស្រុក ។ លោកនាយកអនុវិទ្យាល័យ និងអ្នកភូមិមួយចំនួនបានទៅសុំខ្ចីសៀវភៅទស្សនាវដ្ដីពីគាត់ ពីព្រោះអ្នកទាំងអស់នោះមានការចាប់អារម្មណ៍ខ្លាំងពីរឿងប្រវត្តិសាស្ត្រខ្មែរក្រហម ។

*វណ្ណៈ* ភ្នំដីតាពេជ្រ គឺជាកន្លែងសម្លាប់ដែលក្រុមស្រាវជ្រាវដែនទីរណ្ដៅសាកសពរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាមិនទាន់បានទៅដល់ ។ នៅថ្ងៃអនាគត គម្រោងនៃការធ្វើដែនទីនេះអាចនឹងចុះទៅធ្វើការស្រាវជ្រាវទីកន្លែងនេះ ដើម្បីបំពេញបន្ថែមនូវព័ត៌មានដែលមានរួចមកហើយ ។

*ការចាប់អារម្មណ៍របស់លោកគ្រូ-អ្នកគ្រូ* ៖ រស់ ចាន់ថន ជាគ្រូបង្គោលថ្នាក់ខេត្តមកពីខេត្តតាកែវ ។ អ្នកគ្រូបានជួយទាក់មេឃុំកំពែង ដើម្បីរៀបចំកន្លែងប្រារព្ធវេទិកា ។ ពេលទទួលទានបាយពេលល្ងាចជាមួយអ្នកគ្រូ ចាន់ថន គាត់បាននិយាយថាគាត់បានប្រើប្រាស់សៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅក្នុងថ្នាក់ ។ ទាក់ទងនឹងបញ្ហានេះ សិស្សរបស់គាត់មានការចាប់អារម្មណ៍នឹងសៀវភៅនេះខ្លាំងណាស់ ប៉ុន្តែសៀវភៅនេះមិនមានគ្រប់គ្រាន់ទេ ។ គាត់បានលើកទឹកចិត្តសិស្សឲ្យខ្ចីសៀវភៅពីបណ្ណាល័យមកអាន ។ អ្នកគ្រូ ចាន់ថន បាននិយាយថា សៀវភៅមួយចំនួនបានរក្សាទុកនៅក្នុងបណ្ណាល័យ ។ គាត់ជឿជាក់ថាសៀវភៅនេះ នឹងមានប្រយោជន៍ក្នុងការចែករំលែកការសិក្សារបស់សិស្ស ហើយគាត់ក៏បានចែកសៀវភៅនោះដល់សិស្សផងដែរ ។

បូលី បានពិភាក្សាពីបញ្ហាប្រឈមខ្លះៗដែលអ្នកគ្រូ ចាន់ថន ជួបប្រទះក្នុងពេលវគ្គបណ្តុះបណ្តាលគ្រូមូលដ្ឋាននៅខេត្តពោធិ៍សាត់ ។ អ្នកគ្រូបានបញ្ជាក់ថា ទោះបីជាគាត់ជាអ្នកបណ្តុះបណ្តាលក៏ដោយ ប៉ុន្តែគាត់បានយល់ដឹងជាច្រើនពីវគ្គបណ្តុះបណ្តាលនៅខេត្តពោធិ៍សាត់ ក៏ដូចជារៀនពីអ្នកបណ្តុះបណ្តាលដូចគ្នា និងសិក្ខាកាមឯទៀត ។ គ្រូខ្មែរបានផ្តល់ឧទាហរណ៍មួយចំនួន និងសិក្ខាកាមដែលបានអនុវត្តការបង្រៀនគំរូនៅពេលរសៀល ។ យោងតាមការសង្កេតរបស់គាត់ អ្នកគ្រូជឿជាក់ថា កម្មវិធីបណ្តុះបណ្តាលគ្រូគឺមានរយៈពេលខ្លី ដែលមានន័យថាពុំមានពេលវេលាគ្រប់គ្រាន់ក្នុងការពន្យល់វិធីសាស្ត្រនៅក្នុងសៀវភៅណែនាំគ្រូបង្រៀនឲ្យកាន់តែច្បាស់ថែមទៀត ។ អ្នកគ្រូបានសំណូមពរថា គួរតែមានពេលវេលាច្រើនសម្រាប់ការធ្វើបទបង្ហាញពីវិធីសាស្ត្រនីមួយៗ ។ បន្ថែមពីនេះទៀត គ្រូខ្មែរទាំងអស់គួរតែត្រូវបានរំឭកពីវិធីសាស្ត្រឡើងវិញមុនមួយថ្ងៃ មុនពេលដែលខ្លួនត្រូវឡើងធ្វើបទបង្ហាញនៅថ្ងៃបន្ទាប់ ។

*ការចែកចាយសៀវភៅ:* នៅក្នុងវេទិកានេះ លោក ម៉ែន សង្ហា ជានាយកអនុវិទ្យាល័យសុខអាន ភ្នំ មកជួបជាមួយលោក ឌី ខាំបូលី និងបាននិយាយថា គាត់មានចិត្តសប្បាយរីករាយណាស់ដែលសិស្សរបស់គាត់បានចូលរួមនៅក្នុងវេទិកានេះ ។ សាលារបស់គាត់បានទទួលសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យចំនួនប្រហែល១០០ក្បាល ពេលដែលមជ្ឈមណ្ឌលឯកសារកម្ពុជាចុះមកចែកនូវសៀវភៅនោះក្នុងឆ្នាំ២០០៨ ។ កម្មវិធីចែកសៀវភៅនេះបានធ្វើឡើងនៅវិទ្យាល័យ ជា ស៊ីម តាកែវ ដែលមានទីតាំងនៅក្នុងទីរួមខេត្តតាកែវ ហើយលោកផ្ទាល់ក៏បានចូលរួមក្នុងកម្មវិធីនោះដែរ ។ គាត់បាននិយាយថា សិស្សពុំទាន់មានសៀវភៅនេះ ដើម្បីសិក្សាឲ្យបានគ្រប់គ្រាន់នៅឡើយទេ ។ ដូច្នេះវេទិកានេះមិនត្រឹមតែបានផ្តល់ចំណេះដឹងអំពីប្រវត្តិសាស្ត្រខ្មែរក្រហមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានចែកចាយសៀវភៅប្រវត្តិសាស្ត្រនេះបន្ថែមទៀតដល់សិស្សានុសិស្សដែរ ។ សំខាន់ជាងនេះទៅទៀត លោកនាយកអនុវិទ្យាល័យបានប្រាប់ក្រុមការងារថា គាត់បានណែនាំគ្រូរបស់គាត់ឲ្យបញ្ចូលពីការបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហមទៅក្នុងកម្មវិធីបង្រៀនប្រចាំថ្ងៃរបស់គាត់លើមុខវិជ្ជាប្រវត្តិវិទ្យា ភូមិវិទ្យា អក្សរសាស្ត្រខ្មែរ ពលរដ្ឋវិទ្យា សិល្បៈ និងសីលធម៌ពលរដ្ឋ ។

អៀ ផន ជាប្រធានភូមិវត្តភ្នំ បានចែករំលែកបទពិសោធន៍របស់គាត់ក្នុងរបបខ្មែរក្រហមដល់អ្នកចូលរួមទាំងអស់ ។ គាត់បាននិយាយថា គាត់ចង់និយាយរឿងរ៉ាវរបស់គាត់ឆ្លងកាត់របបខ្មែរក្រហមឲ្យបានច្រើន ប៉ុន្តែគាត់មិនដឹងថាត្រូវចាប់ផ្តើមពីកន្លែងណា និងក្នុងពេលវេលាអ្វី ។ ផន បានថ្លែងអំណរគុណដល់ក្រុមការងារទាំងអស់ដែលបានផ្តល់ឱកាសដល់គាត់បាននិយាយប្រវត្តិរឿងរ៉ាវរបស់គាត់ប្រាប់ដល់សិស្សានុសិស្សបានស្តាប់ ។ បន្ទាប់ពីបានរៀបរាប់ពីប្រវត្តិរបស់គាត់រួចមក គាត់មានអារម្មណ៍ធូរស្បើយច្រើន ប្រៀបដូចជាបានបោះដុំថ្មមួយដុំដ៏ធំចេញពីខ្លួនប្រាណរបស់គាត់អញ្ចឹង ។

ម៉្យាងវិញទៀត ដោយបានស្វែងយល់ពីបញ្ហាប្រឈមពីមុនមក ក្រុមការងារបានយកចិត្តទុកដាក់ច្រើនទៅលើអ្នកភូមិ ក៏ដូចជាសិស្សដែរ ។ ការធ្វើរបៀបនេះ បានលើកទឹកចិត្តគាត់បញ្ចេញមតិ និងចែករំលែកបទពិសោធន៍ផ្ទាល់ខ្លួនដល់សិស្សានុសិស្ស ដូចដែល ផន បានធ្វើអញ្ចឹង ។

*សោកនាដកម្មរបស់ស្ត្រីៈ* ក្រុមការងារបានដឹងថា ក្នុងចំណោមស្ត្រីមួយចំនួនដែលបានចូលរួមនៅក្នុងវេទិកានេះ គឺជាស្ត្រីមេម៉ាយ ។ ពេលដែលក្រុមការងារសួរអ្នកទាំងនោះ ក្នុងពេលបំពេញតារាងស្ទាបស្ទង់មតិមុនពេល និងក្រោយពេលធ្វើវេទិកា ទោះជាអំពើឃោរឃៅបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យក៏ដោយ ក៏ស្ត្រីភាគច្រើនបានប្រាប់ថា «ចាំ! ពីព្រោះប្តីរបស់ខ្ញុំត្រូវបានសម្លាប់» ។ ក្រុមការងារក៏ដឹងទៀតថា មានអង្គការមួយបានផ្តល់ជាជំនួយដល់ពួកគាត់ដែលមានសមាជិកណាម្នាក់ ឬច្រើននាក់នៅក្នុងគ្រួសារត្រូវបានស្លាប់ក្នុងអំឡុងពេលខ្មែរក្រហម ។ ស្ត្រី៣នាក់មកជួបនឹងលោក ឌី ខាំបូលី ដើម្បីរៀបរាប់ពីការតូចចិត្តដែលមិនបានទទួលជំនួយនេះ ។

*ចំណេះដឹងក្នុងប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យៈ* ក្រុមការងារបានឲ្យដឹងថាអ្នកទាំងអស់ដែលបានចូលរួមក្នុងវេទិកានេះ រួមទាំងអ្នកនៅរស់កាលពីរបបខ្មែរក្រហមផង មិនបានដឹងពីហេតុផលថាហេតុអ្វីបានជាខ្មែរក្រហមសម្លាប់ប្រជាជនច្រើនបែបនេះទេ ។ នេះជាការចាប់ផ្តើមពីរបបខ្មែរក្រហមនៅប្រទេសកម្ពុជា ។ ពេលដែលក្រុមការងារសួរថា តើអ្នកទាំងអស់គ្នាដឹងដែរឬទេថា ហេតុអ្វីបានជាខ្មែរក្រហមសម្លាប់ប្រជាជន ។ អ្នកចូលរួមមួយចំនួនបាននិយាយថា «ខ្មែរក្រហមសម្លាប់អ្នកដែលមានចំណេះដឹង និងទុកតែអ្នកដែលមិនចេះអក្សរ ក៏ព្រោះតែអ្នកអស់នោះងាយស្រួលក្នុងការបង្ហាត់បង្រៀន» ។ ចម្លើយនេះមិនខុសទេ ប៉ុន្តែចម្លើយបែបនេះបានបង្ហាញពីចំណេះដឹងដែលនៅមានកម្រិត ដែលទាំងប្រជាជនធម្មតា និងគ្រូបង្រៀនត្រូវតែស្វែងយល់បន្ថែម ។

*ការផ្សព្វផ្សាយរបស់គម្រោងស្តីពីការសិក្សាពីរបបកម្ពុជាប្រជាធិបតេយ្យៈ* ដោយឮថា មជ្ឈមណ្ឌលឯកសារកម្ពុជាបាននិងកំពុងបង្កើតវេទិកាសាធារណៈស្តីពីប្រវត្តិសាស្ត្រខ្មែរក្រហម អ្នកភូមិ លោកគ្រូអ្នកគ្រូ និងសិស្សានុសិស្សដែលបានទទួលសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ បានចាប់ផ្តើមចែករំលែកសៀវភៅនេះទៅឲ្យគ្នាអានម្តងម្នាក់ៗ ។ ក្រុមការងារបានទទួលទានអាហារថ្ងៃត្រង់នៅផ្ទះអ្នកភូមិ ។ ក្នុងពេលកំពុងញ៉ាំអាហារ បូលី បានឃើញសៀវភៅប្រវត្តិសាស្ត្រមួយក្បាលដែលសន្លឹកសៀវភៅនេះមានសភាពពុកផុយទៅហើយ ។ បូលី បានសួរទៅកាន់ រ៉ាទី ជាកូនស្រីរបស់អ្នកភូមិម្នាក់ថា តើប្អូនបានសៀវភៅនេះមកពីណា? នាងក៏បាននិយាយថា ខ្ញុំបានខ្ចីសៀវភៅនេះពីអ្នកគ្រូមកអាន ពីព្រោះនាងបានឮថា ក្រុមការងារយើងបានមកធ្វើការនៅក្នុងភូមិរបស់នាង ។ នាងបានអានចប់ជំពូក២ ។ នាងបានសរសើរពីការប្រមូល នឹងការការពាររបស់រូបថតចាស់ៗទាំងនោះ ។ បន្ទាប់មកនាងក៏បានរំឭកពីការសិក្សារបស់នាងនៅឯសាលា ។ នាងមានការចងចាំថា នាងបានសួរទៅកាន់គ្រូរបស់

នាងនូវសំណួរ “តើបក្សកុម្មុយនីស្តកម្ពុជាគឺជាអ្វី”? គ្រូរបស់នាងបានពន្យល់ថា “បក្សកុំម្មុយនីស្តគឺជាក្រុមទាហានដែលចង់ផ្តួលរំលំស្តេចនៅជំនាន់នោះ” ។ នាងបាននិយាយថា នាងជឿទាំងស្រុងនូវអ្វីដែលគ្រូរបស់នាងបានប្រាប់ ។ បូលី បានប្រាប់នាងឲ្យអានសៀវភៅតាំងពីដើមរហូតដល់ចប់ នឹងស្វែងរកថាតើអ្វីទៅជារបបកុំម្មុយនីស្ត ។

**បញ្ហាប្រឈមៈ**

***ការខ្វះខាតក្នុងការទំនាក់ទំនងៈ*** *លោកមេឃុំ បានទទួលពត៌មានពីមជ្ឍមណ្ឌលឯកសារកម្ពុជា ដែលក្រុមការងារបានចុះទៅកាន់ទីនោះ ដើម្បីប្រារព្ធនូវវេទិកាសាធារណៈស្តីពីការអប់រំ ។ គាត់ក៏បានប្រាប់ទៅកាន់លោកមេភូមិដើម្បីអញ្ជើញប្រជាជនទាំង១៣ភូមិដើម្បីចូលរួមក្នុងវេទិកានេះ ។ មុនថ្ងៃបើកវេទិកាពីរថ្ងៃ លោកមេឃុំចង់ទាក់ទងជាមួយក្រុមការងារ ប៉ុន្តែគ្មានលទ្ធិភាពក្នុងការទាក់ទង ។ ក្រុមការងារចង់ដឹងឲ្យបានច្បាស់ថែមទៀតថា រាល់ការទាក់ទងដើម្បីទទួលបានព័ត៌មានមួយ គឺចាំបាច់ត្រូវធ្វើការទាក់ទងទៅកាន់អាជ្ញាធរមូលដ្ឋាន និងព័ត៌មានដែលត្រូវបានចែកចាយទៅឲ្យមន្ទីរឃុំគឺត្រូវតែច្បាស់លាស់ និងត្រឹមត្រូវ ។*

*នៅក្នុងឱកាសនោះ ក្រុមការងារបានចែកជូននូវទស្សនាវដ្តីស្វែងរកការពិត និងកូនសៀវភៅដែលរៀបរាប់ពីករណី០០២ ដល់អ្នកចូលរួមនៅចុងបញ្ចប់នៃការធ្វើបទបង្ហាញនឹងការពន្យល់ ។ ព្រោះតែហេតុផលទាំងនេះ អ្នកចូលរួមទាំងអស់បានយកចិត្តទុកដាក់ក្នុងការស្តាប់ពីការរៀបរាប់នៅក្នុងសៀវភៅនេះ ។ បើមិនដូច្នេះទេ យើងជឿជាក់ថា អ្នកចូលរួមទាំងអស់អាចនឹងផ្លាស់ប្តូរពីការអានសៀវភៅមួយ ទៅអានសៀវភៅមួយផ្សេងទៀត ជាមួយនឹងការមិនយកចិត្តទុកដាក់ក្នុងមាតិការបស់វេទិកានៅព្រឹកនេះឡើយ ។*

*ក្រុមការងារបានសង្កេតឃើញថា អ្នកចូលរួមទាំងអស់មានការចាប់អារម្មណ៍ខ្លាំងទៅលើ ប្រធានបទមួយនៅក្នុងជំពូក៧ ដូចជាការរៀបអាពាហ៍ពិពាហ៍ ការធ្វើការហួសកម្លាំង និងគៀបសង្កត់លើការគោរពសាសនា ។ ការធ្វើបែបនេះ ហាក់ដូចជាធ្វើឲ្យអ្នកភូមិមានការចូលចិត្តខ្លាំងក្នុងការពិភាក្សាពីប្រធានបទដែលមាននៅក្នុងសៀវភៅប្រវត្តិសាស្ត្រ ភ្ជាប់ទៅនឹងបទពិសោធន៍ជីវិតពិតរបស់ខ្លួនក្នុងរបបខ្មែរក្រហម ។*

*លោកមេឃុំមានការខកចិត្តខ្លះៗចំពោះក្រុមការងារ ។ យោងតាមពិធីការរបស់រដ្ឋាភិបាល មេឃុំដែលធ្វើជាអធិបតីនៅក្នុងវេទិកាណាមួយ គឺត្រូវធ្វើជាគណអធិបតីទាំងពិធីបើក និងបិទវេទិកា ។ នៅចុងបញ្ចប់នៃការធ្វើវេទិកាសាធារណៈនេះ យើងមិនបានផ្តល់ឱកាសឲ្យគាត់ឡើងធ្វើពិធីបិទឡើយ ។ នៅពេលក្រោយ ក្រុមការងារគួរផ្តល់រយៈពេលពីរបីនាទីដើម្បីឲ្យមេឃុំឡើងថ្លែងសន្ទរកថាបិទកម្មវិធី ។ សមាជិកក្រុមការងាររបស់គម្រោង៖*

ឌី ខាំបូលី

ផេង ពង្សរ៉ាស៊ី

ប្រាក់ កែវតារា

លី សុខចំរើន